# គោរពជូន
# សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតី តេជោ នាយករដ្ឋមន្ត្រីជាទីគោរព

តាងនាមឱ្យរដ្ឋាភិបាល និងប្រជាជនជប៉ុន ខ្ញុំសូមអនុញ្ញាត ដើម្បីចូលរួមរំលែកទុក្ខដ៏សែនក្រៀមក្រំជាទីបំផុតជាមួយព្រះរាជវង្សានុវង្ស រាជរដ្ឋាភិបាល និងប្រជាជន នៃព្រះរាជាណាចក្រកម្ពុជា ដោយបានទទួលដំណឹងដ៏សែនរន្ធត់ថា ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បានយាងចូលព្រះទិវង្គត ។

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ បានខិតខំព្យាយាមបំពេញព្រះរាជកិច្ចអស់រយៈពេលមួយជីវិតរបស់ព្រះអង្គ ដើម្បីស្វែងរកឯករាជ្យ សន្តិភាព និងស្ថិរភាពជូនព្រះរាជាណាចក្រកម្ពុជា ។ ជាពិសេសក្នុងដំណើរការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា ព្រះអង្គបានដើរតួនាទីដ៏សំខាន់បំផុតជានិមិត្តរូប នៃឯកភាពជាតិ ដើម្បីសម្រេចបាននូវការបង្រួបបង្រួមជាតិ និងសន្តិភាព ។

ក្នុងវិស័យទំនាក់ទំនងជាមួយប្រទេសជប៉ុន ព្រះអង្គបានកសាងគ្រឹះ នៃទំនាក់ទំនងមិត្តភាពរវាងប្រទេសយើងទាំង ២ សំរាប់អនាគត ដោយបានធ្វើព្រះរាជកិច្ចដូចជា ការយាងមកបំពេញព្រះរាជដំណើរទស្សនកិច្ចជាផ្លូវរដ្ឋនៅប្រទេសជប៉ុននៅឆ្នាំ ១៩៥៥ ហើយបានយល់ដឹងយ៉ាងជ្រាលជ្រៅជាទីបំផុតអំពីវិភាគទានរបស់ប្រទេសជប៉ុន ក្នុងដំណើរការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា ។

ការសោយព្រះទិវង្គតរបស់ព្រះអង្គ ដែលជាមគ្គុទ្ទេសក៍ដ៏ឈ្លាសវៃកម្រមាននេះ និងជាតំណាង នៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងសម័យកាលបច្ចុប្បន្ន គឺជាការបាត់បង់ដ៏ធំធេង និងគួរឱ្យសោកស្តាយជាទីបំផុតមិនមែនសំរាប់តែប្រទេសកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងសម្រាប់សហគមន៍អន្តរជាតិ ជាពិសេសប្រទេសរបស់យើងខ្ញុំផងដែរ ។

ខ្ញុំសូមបួងសួងសូមឱ្យព្រះវិញ្ញាណក្ខន្ធ នៃព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរបានទៅកាន់សុខគតិភព ព្រមទាំងសូមឱ្យព្រះរាជវង្សានុវង្ស រាជរដ្ឋាភិបាល និងប្រជាជន នៃព្រះរាជាណាចក្រកម្ពុជាបានឆ្លងផុតពីឱកាសដ៏មហាសោកសៅនេះ ។

ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១២

ណូដា យ៉ូស៊ីហ៊ីកូ

នាយករដ្ឋមន្ត្រី នៃប្រទេសជប៉ុន